# វប្បធម៌ ចរចារ ឬ ចុះចាញ់ ?

លោក សម-រង្ស៊ី ធ្វើការឃោសនា ថា គណបក្សសង្គ្រោះជាតិ យកវប្បធម៌ចរចាជាមួយ លោក ហ៊ុន-សែន ជាយុទ្ធសាស្ត្រនយោបាយ ព្រោះយុទ្ធសាស្ត្រ នេះ អាចរក្សាសន្តិភាព នៅស្រុកខ្មែរបាន។ តាមការពិសោធ ដែលធ្លាប់មាននៅស្រុកខ្មែរ តាំងពីឆ្នាំ ១៩៩៣ មក បង្ហាញថា «**ចំណង់នូវសន្តិភាព**[1]» គ្រាន់តែជា ការប្រាថ្នា រក្សា ឬ ចែកអំណាច រវាង គូភាគី ជាចំណង់ មាន ភាពផុយស្រួយ និង នាំមក នូវមហន្តរាយ ជានិច្ច ដូចយ៉ាង ការចរចារ បង្កើតរបបរាជានិយមឡើងវិញ (១៩៩៣), ចែកអំណាចដឹកនាំ បង្កើត រដ្ឋាភិបាលក្បាលពីរ (១៩៩៣), ទទួលស្គាល់រដ្ឋប្រហារក្នុងឆ្នាំ ១៩៩៧ ជាទង្វើស្របច្បាប់ រហូតមកដល់ កិច្ចព្រមព្រៀង រវាង គណបក្ស សង្គ្រោះជាតិ ជាមួយនឹង គណបក្សប្រជាជន នា ថ្ងៃទី២២ សីហា ឆ្នាំ ២០១៤ បំពានលើក ឆន្ទៈ ម្ចាស់ឆ្នោត។ វប្បធម៌ចរចារ ដែល លោក សម-រង្ស៊ី លើកយកមកធ្វើ ជាយុទ្ធសាស្ត្រ នេះ គឺជា ការបន្ត នូវបរាជ័យ យុត្តិធម៌ នៅចំពោះមុខ អំណាចផ្តាច់ការតែប៉ុណ្ណោះ។ យើងដឹងថា បើគ្មានយុត្តិធម៌ គឺគ្មាន ជាដាច់ខាត នូវសន្តិភាព ព្រោះ ធម្មជាតិ នៃសន្តិភាព វាផ្ទុយនឹង អំណាចផ្តាច់ការ។

សន្តិភាព មិនគ្រាន់តែ ជាពាក្យផ្អើយ និង សង្គ្រាម តែប៉ុណ្ណោះទេ ព្រោះសារជាតិ នៃសន្តិភាព ជាអានុភាព នៃលទ្ធិប្រជាធិបតេយ្យ ក្នុងនីតិរដ្ឋ ដែលជា ឧបករណ៍ របស់ប្រជាពលរដ្ឋ ជាអធិបតីសំរាប់ បំរើ អំណាចដឹងនាំជាតិ នៃប្រជាពលរដ្ឋ ដើម្បីប្រយោជន៍ ប្រជាពលរដ្ឋ។ សន្តិភាព គ្មាននិតិរដ្ឋ ជាសន្តិភាព របស់ **អំណាច សមស្តនិយម**[2]។ លទ្ធផល នៃការបោះឆ្នោត ថ្នាក់ជាតិ ក្នុងឆ្នាំ ២០១៤ បង្ហាញឲយើញច្បាស់ នូវ **ទ្វិកភាព**[3] ជាគ្រឹះ រវាង «**ចំណង់ នូវការប្តូរ អ្នកដឹកនាំ**» ជាមួយ «**ចំណង់ នូវការរក្សាអំណាចផ្តាច់ការ**»៖ ចំណង់ទី១ យក លទ្ធិប្រជាធិបតេយ្យ ជាការប្រយុទ្ធ ជា **ពាហុយុទ្ធ**[4] រីឯ ចំណង់ទី២ យក **សប្បដិភ័យ**[5] ជា ខែល សំរាប់ការពារអំណាច។ សួរថា តើនៅត្រង់ចំណុចណា ដែលគណបក្សសង្គ្រោះជាតិ យល់ឃើញថា គណបក្សប្រជាជន មានចំណង់នូវសន្តិភាព ?

ក្នុងសភាពបែបនេះ បង្ហាញជាក់ច្បាស់ថា ចំណង់ទាំងពីរនេះ ពុំអាច រួមរស់ ជាមួយគ្នាបាននោះឡើយ នៅក្នុង សន្តិភាព គ្មាន នីតិរដ្ឋ ដែលជាសន្តិភាព សំរាប់តែអ្នកដឹកនាំ រស់ក្នុងជម្ងឺ **ឆ្កួតយួន**[6] ដែលជា ជម្ងឺ **អសតេកិច្ចរោគ**[7] គឺឆ្កួតនឹង ស័ក្តិយស អំណាច និង អំពើពុករលួយដើម្បីបំរើប្រយោជន៍យួន។ វប្បធម៌ចរចារ នៃគណបក្សសង្គ្រោះជាតិ ដែលគ្រាន់តែជាការចម្លងសុទ្ធសាធ ពី វប្បធម៌ របស់ស្តេចសីហនុ និង គណបក្សហ្វុនស៊ិនប៉ិច ដែលបានធ្លាប់អនុវត្តិ ចាញ់ជានិច្ច តាំងពីឆ្នាំ១៩៩៣ មកម្លេះ គឺ ជា ការពត់ ឲកោង ឬ ឲបាក់ ដើម្បីបំរើ ប្រយោជន៍ គណបក្សប្រជាជន នូវសេចក្តីសង្ឃឹម នៃប្រជាពលរដ្ឋខ្មែរ ដែលមានចំណង់ ចង់រស់ ក្នុង សុភមង្គល ជា

[1] ចំណង់នូវសន្តិភាព= Désir de paix។
[2] អំណាច សមស្តនិយម= អំណាច ត្រួតត្រា លើគ្រប់វិស័យសង្គម ទាំងផ្នែកសាធារណៈ និងឯកជន ; Pouvoir totalitaire។ អំណាចនេះ បង្កើតឡើង នៅក្នុងរបប Adolf Hitler និង Joseph Staline។
[3] ទ្វិកភាព= ការប្រឆាំងទុលមុខគ្នា រវាងអង្គពីរ ឬ វត្ថុធាតុពីរផ្សេងគ្នា ; Dualité។
[4] ពាហុយុទ្ធ= ប្រយុទ្ធគ្មានអាវុធ ; Lutter à mains nues។
[5] សប្បដិភ័យ= បំភ័យខ្លាំង ; Terreur។
[6] ឆ្កួតយួន ជាអតិសុខុមប្រាណ ដែលយួនគេយកមកចាក់ក្នុងឈាមអ្នកដឹកនាំខ្មែរឲមានជម្ងឺឆ្កួតបិយាំង។
[7] អសតេកិច្ចរោគ= រោគពុំអាចជាបាន ; Maladie incurable។

មនុស្ស មាន «សេរីភាព» ដែលជា ពន្លឺបំភ្លឺ **ចតុទ្ទិស**[8] នៃប្រជាជាតិខ្មែរ ដូចជានិមិត្តរូប នូវភ្លើងចន្លុះ នៃ «**បដិមាករ នៃសេរីភាព**» នៅសហរដ្ឋអាមេរិក ដែលជាភ្លើងបំភ្លឺសេរីភាព នៅក្នុង ពិភពលោក។ សេរីភាព ជា ធាតុរបស់មនុស្សលោក បំបាត់សេរីភាព គឺជាការបន្ថយ ធម្មជាតិ មនុស្សលោក ឲមកនៅត្រឹមតែជា សត្វធាតុ។ ហេតុនេះឯង បានជាគេឃើញមានជានិច្ច ការកើត «**កំហឹង**» នៃមនុស្សលោក នៅទីណា ដែលសេរីភាព មានការគំរាបកំហែងពី កម្លាំងអ្វីមួយ។ កំហឹងប្រឆាំងនឹង **និគ្រោះ**[9] មិនមែនជា ការបះបោល ឬជាកុបកម្មប្រឆាំង នឹង អំណាចរដ្ឋ ឬ សត្រូវ ណាមួយឡើយ ព្រោះ «**ចំណង់នូវសេរីភាព**» មិនមែនជាកម្លាំងយោធា ឬ **យុទ្ធកៈ**[10] តស៊ូ ដើម្បី យក អំណាច មកកាន់កាប់ នោះឡើយ តែជាកំហឹងកម្រើកបិតថេរទាំង ផ្លូវចិត្ត ទាំងផ្លូវកាយ នៅទីណា ដែលសេរីភាព ទទួលការសង្កត់សង្កិន។ ជាកម្លាំងអហឹង្សា ជា**សយម្ភូត**[11] ដោយចេតនា តែគ្មានការរៀបចំ ជា កម្លាំងប្រដាប់អាវុធព្រោះគ្មានគោលបំណងនឹង ធ្វើសង្គ្រាមអ្វីនោះទេ តែជា **កម្លាំងរំពើក**[12] មិនព្រមចុះចាញ់ មិនរំសាយនៅតែ ប្រកែកតវ៉ា រក យុត្តិធម៌ ជានិច្ច នៅចំពោះមុខ កម្លាំង សង្កត់សង្កិន។ សេចក្តីស្វិតស្វាញ សេចក្តីរឹងរូស សេចក្តី ក្លាហាន នៅបិតថេរ ជានិច្ច បង្កើតបាន ជាកម្លាំងតស៊ូ មិនអាចទុបទល់បាន ប្រកបដោយ អានុភាព មិនអាចសាបសូន្យ ហេតុនេះឯង បានជាគេទុកកំហឹង ប្រឆាំងនឹង កម្លាំង និគ្រោះ ជា គុណធម៌ នៃ កម្លាំងតស៊ូ មួយ ប្រឆាំងនឹង អំណាចផ្តាច់ការ។ គេអាចទុក ការតស៊ូ បែបនេះ ជាបដិវត្តន៍ អហឹង្សា ដែលមានប្រជាជន ជានាដការ សកម្ម ប្រមែប្រមូលកំហឹង រៀបចំ ឲក្លាយជា កម្លាំងប្រជាប្រិយ តស៊ូ អហឹង្សា ដើម្បីរក្សាធាតុ សេរីភាព របស់មនុស្សលោក និង ធ្វើឲបាន ចម្រើន នូវលទ្ធិប្រជាធិបតេយ្យ។

សួរថាតើនៅត្រង់ចំណុចណាមួយ ដូចបានរៀបរាប់ខាងលើនេះ ដែលគណបក្សសង្គ្រោះជាតិ លើកយក វប្បធម៌ចរចារ ថាជា មធ្យោបាយ តែមួយគត់ ដើម្បី ជៀសវាង កុំឲមានសង្គ្រាម ? តើ នរណា ជាអ្នកបង្កើតសង្គ្រាម ? ការប្រើ **កម្លាំងសិទ្ធិអាជ្ញា**[13] (យោធា, នគបាល) ដើម្បី សង្កត់សង្កិន ប្រជាជន មិនអាចទុកបាន ជា អំពើ សង្គ្រាម នោះឡើយ ព្រោះ អំពើសង្គ្រាម ជា ការប្រយុទ្ធ តាមផ្លូវអាវុធ រវាង សត្រូវ ជាមួយនឹង សត្រូវ ; តែថា ប្រជាជន មិនបានទុក រដ្ឋ ជា សត្រូវ នឹងខ្លួននោះឡើយ ហើយការតស៊ូប្រឆាំងនឹង កម្លាំងនិគ្រោះ តាមសន្តិវិធី គឺធ្វើឡើង ក្នុង ក្របខណ្ឌ លិទ្ធិប្រជាធិបតេយ្យ សុទ្ធសាធ ដូច្នេះ ការប្រើកម្លាំងសិទ្ធិអាជ្ញា ប្រឆាំងនឹង ការ តស៊ូ របស់ប្រជាជន ដើម្បី យុត្តិធម៌ ជា **អំពើ ភេរវកម្ម នៃរដ្ឋ**[14]។ ការចរចារ ជាមួយ ភេរវជនមិន មានន័យថា ជាការរក សន្តិភាព ព្រោះថា៖ ទី១ អំពើ ភេរវកម្ម មិនមែនជាសង្គ្រាម, ទី២ ការ ចរចារ ជាមួយ ភេរវជន ជាការទទួលស្គាល់ ច្បាប់ព្រៃ ឬ បទដ្ឋានឃោរឃៅ របស់វា។ ដូច្នេះ សន្តិភាព ដែលកើតមានឡើង នៅក្នុង គ្រោងបែបនេះ ជាសន្តិភាព សំរាប់តែ រកសេចក្តីសុខ រវាង គូភាគី តែប៉ុណ្ណោះ តែនៅក្នុងសន្តិភាពបែបនេះ វាមានអ្នករងគ្រោះនឹង ច្បាប់ព្រៃ គឺ ប្រជាជន ស្រឡាញ់ យុត្តិធម៌ និង សេរីភាព។

[8] ចតុទ្ទិស= Les Quatre points cardinaux។
[9] និគ្រោះ=ការបងក្រាប ; Répression។
[10] យុទ្ធិកៈ= អ្នកសកម្មប្រយុទ្ធ ; Militant។
[11] សយម្ភូត=ដែលធ្វើទៅដោយឯងៗ ; Spontané។
[12] កម្លាំងរំពើក= កម្លាំងញ័ររញ្ជួយ ; Force tremblante។
[13] កម្លាំងសិទ្ធិអាជ្ញា= កម្លាំង របស់រដ្ឋ ; Force régalienne។
[14] អំពើភេរវកម្មនៃរដ្ឋ= Acte de terrorisme de l’Etat។

មួយវិញទៀត ការលើកយក ការជៀសវាង សង្គ្រាម មកធ្វើជា យុត្តិកម្ម ក្នុងការចរចារ ជាការ លើកយក ពាក្យ សង្គ្រាម មកបំភ័យ ដល់ប្រជាជន ថាបើ មិនចរចារ គឺនឹងមានកើតសង្គ្រាម។ សុំសួរម្តងទៀត ថា តើ មាន សង្គ្រាម ជាមួយនរណា ? វប្បធម៌ ចរចារ របស់ គណបក្សសង្គ្រោះជាតិគ្រាន់ជា ការបិទបាំង បរាជ័យ របស់អ្នកដឹងនាំគណបក្ស ព្រោះខ្លួន ភ័យសស្លោ នៅចំពោះមុខ ការគំរាបកំហែង ឬ ការសម្លុត របស់ ពួកអ្នកដឹងនាំផ្តាច់ការ។ ត្រូវដឹងថា ការភ័យខ្លាច មិនមែនមាននៅក្នុង ធម្មជាតិ នៃមនុស្សលោក ជាពិសេស ក្នុងធម្មជាតិ អ្នកដឹកនាំនោះទេ។ ការភ័យខ្លាច ជាជម្រើស នៅចំពោះមុខ ការគំរាបកំហែង អ្វីមួយ។ ជម្រើស ព្រោះភ័យខ្លាច នេះហើយ ដែលលោក សម-រង្សី និង កែម-សុខា ជ្រើសយកវាមកធ្វើជា ដំណោះស្រាយ ដើម្បី សេចក្តីសុខ សំរាប់ តែអាត្មា និង អត្ថប្រយោជន៍។ ការចរចារ ក្នុងជម្រើសបែបនេះ មិនមែនជាការចរចារ នោះឡើយ, តែ ជាការបន្តការចុះចាញ់ជានិច្ច ដែលមានតាំងពីឆ្នាំ១៩៩៣ មកម្លេះ ដែលជាទង្វើ បំផ្លាញ សេរីភាព និង លទ្ធិប្រជាធិបតេយ្យ។ តែបើប្រជាជនខ្មែរ យល់ឃើញថា ការចរចារ ជាមធ្យោបាយ ដើម្បីរក្សា សន្តិភាព ហើយនាំគ្នា ដេកចាំ ការបោះឆ្នោត នាឆ្នាំ ២០១៨ ដែល លោក សម-រង្សី និង កែម-សុខា កំពុង ឃោសនា ដើម្បី បំរើសេចក្តីសុខ ដល់លោក ហ៊ុន-សែន គឺច្បាស់ជា នាំគ្នាដេកចាំ **សេចក្តីអស់សង្ឃឹម** បន្តទៅទៀត ដែលជាពេលវេលាមួយ សំរាប់ ជនជាតិយួន យកទឹកដីខ្មែរ ធ្វើជា ផ្ទះរបស់យួន។ នៅស្រុកខ្មែរ **មានអាសន្នមួយ គឺ ហានិភ័យយួន**[15] ដូច្នេះ ខ្មែរមិនអាចបន្ត ការពីសោធ ដែលធ្លាប់តែចាញ់ជានិច្ចនោះបានទៀតឡើយ។ ដេកចាំ ឆ្នាំ ២០១៨ គឺពិតជា កំពុងនាំគ្នា សម្លាប់ខ្លួន ដើម្បីប្រគល់ទឹកដីដូនតាខ្លួន ទៅ៲ ជនជាតិយួន តែប៉ុណ្ណោះ។ ដូច្នេះ វប្បធម៌ចរចារ របស់ គណបក្សសង្គ្រោះជាតិ ជានយោបាយ បំរើប្រយោជន៍យួន សុទ្ធសាធ។ ខ្មែរ អ្នកស្រឡាញ់ជាតិ ដឹកច្បាស់ណាស់ ថាខ្លួនត្រូវធ្វើអ្វីនៅចំពោះមុខ ហានិភ័យយួន នេះ គឺ ត្រូវនាំគ្នា បង្កើត កម្លាំងរំពើក  មិនព្រមចុះចាញ់ មិនរំសាយ នៅតែ ប្រកែកតវ៉ា រកយុត្តិធម៌ ជានិច្ច នៅចំពោះមុខ កម្លាំង សង្កត់សង្កិនដើម្បីធ្វើ បដិវត្តន៍ អហឹង្សា។ សម្រេក នៃកំហឹង ជនជាតិខ្មែរ ប្រឆាំងនឹង អំណាចផ្តាច់ការជា ការសង្គ្រោះជាតិ ពិតប្រាកដ មិនមែន យក វប្បធម៌ចរចារ ក្នុងជម្រើស ភ័យសស្លោ មកធ្វើជា មធ្យោបាយសង្គ្រោះជាតិ ដូច គណបក្សសង្គ្រោះចោរ នោះឡើយ។ លោក សម-រង្សី និង កែម-សុខា គាត់នាំគ្នាពាក់ងារជាកិត្តិយស ដែលជាច្រវាក់ ចងរឹតគាត់ ឲរស់នៅមាត់ទ្វារគុក របស់លោក ហ៊ុន-សែន ; បើហ៊ាន ប្រកែក តែមួយមាត់ គឺច្បាស់ ជា លោក ហ៊ុន-សែន បញ្ជូលភ្លាម ទៅរស់ ក្នុងគុកព្រៃស ស្របតាម កិច្ចព្រមព្រៀង ថ្ងៃទី ២២ សីហា ឆ្នាំ ២០១៤ រវាង គណបក្ស សង្គ្រោះជាតិ ជាមួយនឹង គណបក្សប្រជាជន។ នេះហើយ លទ្ធផល វប្បធម៌ ចរចារ ឬ ចុះចាញ់ របស់ ឯកឧត្តម សម-រង្សី និង កែម-សុខា។

ឧប សៅ សង្ហា

១៦ កុម្ភះ ឆ្នាំ ២០១៥

[15] ហានិភ័យយួន= Péril vietnamien។